23 មិថុនា 2017



# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការរៀបចំគោលនយោបាយជាតិ ស្តីពីភាសានិងអក្សរខ្មែរ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំគោលនយោបាយជាតិស្តីពីភាសានិងអក្សរខ្មែរនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ | ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត នៅ ស៊ុន | អនុប្រធានប្រចាំការក្រុមប្រឹក្សាជាតិភាសាខ្មែរ | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត សន ពៅ | អគ្គលេខាធិការក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ៤- ឯកឧត្តម ឈន អៀម | អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ៥- ឯកឧត្តមបណ្ឌិត ជួរ គារី | អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ៦- ឯកឧត្តមបណ្ឌិត ហ៊ោ គឿន | អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ៧- ឯកឧត្តមបណ្ឌិត ស៊ុំ ឈុំឡុង | អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ៨- ឯកឧត្តម ប៊ុត សុម៉េត | អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ៧- លោក លាង សុភាព | ប្រធានផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ | សមាជិក |
| ៩- លោក សេ អឿន | ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយ និងបណ្ណុះបណ្តាល | សមាជិក |
| ១០- លោកស្រី ហង់ លក្ខិណា | អនុប្រធានផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ | សមាជិកា |
| ១១- លោក ជួន សោរិទ្ធី | អនុប្រធានផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ | សមាជិក |
| ១២- លោក គឹម សុវត្ថិ | អនុប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយ និងបណ្ណុះបណ្តាល | សមាជិក |
| ១៣- លោកបណ្ឌិត ម៉ុក សារ៉ែម | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៤- លោក អោ សៀម | ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៥- លោក ផង់ ភិរុណ | ជំនួយការអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិភាសាខ្មែរ | លេខាទទួលបន្ទុកហិរញ្ញកិច្ច។ |

**ប្រការ២.-**

គណៈកម្មការនេះមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំស្រាវជ្រាវនិងចងក្រងឯកសារពាក់ព័ន្ធនឹងគោលនយោបាយជាតិស្តីពីភាសានិងអក្សរខ្មែរ
- សិក្សាធាតុចូលសម្រាប់គោលនយោបាយជាតិស្តីពីភាសានិងអក្សរខ្មែរ
- រៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីភាសានិងអក្សរខ្មែរ ដោយឈរលើស្មារតីអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ
- រៀបចំឯកសារគោលនយោបាយដើម្បីដាក់ឆ្លងសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាជាតិភាសាខ្មែរប្រគល់ជូន។

**ប្រការ៣.-**

ប្រធានគណៈកម្មការ មានសិទ្ធិអញ្ជើញសមាជិកចូលរួមប្រជុំតាមការចាំបាច់។

ប្រធានគណៈកម្មការនេះ មានសិទ្ធិតែងតាំងអ្នកជំនាញមួយចំនួន ជាជំនួយការ តាមការចាំបាច់។

**ប្រការ៤.-**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ និងមានកញ្ចប់ថវិកាដោយឡែក ដូចមានចែងក្នុងលិខិតលេខ១២៣៧ សជណ.ផហ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្ត សេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ